# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍**

## របាយការណ៍
## កិច្ចប្រជុំ
## ស្តីពីការអភិវឌ្ឍន៍ប្រព័ន្ធសូចនាករ និងការតាមដានរួម

ឆ្នាំពីរពាន់ប្រាំពីរ ខែ សីហា ថ្ងៃទី ប្រាំបី វេលាម៉ោងប្រាំបួនព្រឹកនៅសាលប្រជុំរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ មានរៀបចំកិច្ចប្រជុំមួយក្រោមអធិបតីភាពរបស់ឯកឧត្តម **ស៊ុំ ម៉ានិត** ប្រធានអង្គភាពសម្រប សម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដើម្បីពិនិត្យ និងពិភាក្សាអំពីការអភិវឌ្ឍន៍ប្រព័ន្ធសូចនាករ និងការតាមដានរួម។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់មកជាមួយ ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ស៊ុំ ម៉ានិត** បានសម្តែងការស្វាគមន៍ចំពោះអង្គប្រជុំ និងបានមានប្រសាសន៍ថា ការប្រជុំថ្ងៃនេះ គឺធ្វើបន្តពីថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៧ ដោយមូលហេតុសមាជិកចូលប្រជុំនាពេលនោះ មិនទាន់យល់ច្បាស់អំពីការអភិវឌ្ឍន៍ប្រពន្ធ័សូចនាករ និងការតាមដានរួម (Indicator & Monitoring System) នោះ ដែលមានអក្សរកាត់ថា IMS។ ឯកឧត្តមប្រធានបានមានប្រសាសន៍បន្តថា ក្នុងពេលនេះយើងស្ថិតនៅក្នុងជំហ៊ានទីពីរ នៃការរៀបចំប្រព័ន្ធ IMS។ ជាបន្ទាប់ឯកឧត្តមបានប្រគល់វេទិកាជូនឯកឧត្តម **ស៊ុយ ម៉ុងលាង** ដើម្បីធ្វើការពន្យល់បកស្រាយពីការរៀបចំប្រព័ន្ធសូចនាករ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោងបានមានប្រសាសន៍ថា ការប្រជុំនាថ្ងៃនេះ គឺមាន គោលបំណងជម្រាបជូនឡើងវិញអំពីបច្ចេកទេសរៀបចំ «ប្រព័ន្ធសូចនាករ»។ ជាបន្ទាប់ឯកឧត្តមបានធ្វើបទឧទ្ទេសនាម ជូនអង្គប្រជុំអំពីការអភិវឌ្ឍន៍ប្រព័ន្ធសូចនាករ និងការតាមដានរួមតាមរយៈការបញ្ចាំងស្លាយ ដូចជូនភ្ជាប់មកជាមួយ។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានថ្លែងអំណរគុណចំពោះឯកឧត្តម **ស៊ុយ ម៉ុងឈាង** ដែលបានពន្យល់យ៉ាងក្បោះក្បាយអំពីការរៀបចំប្រព័ន្ធ IMS ហើយឯកឧត្តមមានប្រសាសន៍ថា ក្រោយពីបានស្តាប់បានអាន និងការពន្យល់បង្ហាញនេះមក ឯកឧត្តមហាក់ដូចជាបានយល់ច្រើនជាងមុន។ ឯកឧត្តមប្រធានបានសុំឱ្យឯកឧត្តម **ស៊ុយ ម៉ុងឈាង** ជម្រាបសារជាថ្មី អំពីការចាត់ចែងក្រុមការងារសម្រាប់ការរៀបចំប្រព័ន្ធ IMS នេះ តើយើងចាត់តាំងក្រសួងណា ស្ថាប័នណា កំរិតណា?

ឯកឧត្តម **ស៊ុយ ម៉ុងឈាង** បានជម្រាបអង្គប្រជុំថា តំណាងជាន់ខ្ពស់របស់ក្រសួង ស្ថាប័ន ដែលអញ្ជើញចូលរួមប្រជុំនៅថ្ងៃនេះ នឹងត្រូវបានអញ្ជើញចូលជាសមាជិករបស់ក្រុមការងារជាន់ខ្ពស់ សម្រាប់គម្រោងប្រព័ន្ធសូចនាករនេះ។ បន្ទាប់មកយើងខ្ញុំនឹងសូមឱ្យក្រសួង ស្ថាប័នចាត់តាំងមន្ត្រីថ្នាក់បច្ចេកទេសដើម្បីចូលជាសមាជិកនៃក្រុមការងារបច្ចេកទេស ដូចដែលយើងបានធ្វើសម្រាប់គម្រោងតុលាការគំរូដែរ។

ឯកឧត្តម **ប្រុក សារឿន** ប្រធានក្រុមនីតិកម្មនៃក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា កន្លែងខ្លះយល់ស៊ីជម្រៅ ប៉ុន្តែកន្លែងខ្លះមិនសូវយល់នៅឡើយអំពីការងារកែទម្រង់នេះ។ ឯកឧត្តមមានយោបល់ថា មុននឹងឈានទៅដល់ប្រព័ន្ធសូចនាករ សូមឱ្យរៀបចំរចនាសម្ព័ន្ធរដ្ឋបាលជាមុនសិន ជាពិសេសសូមឱ្យមានការចាត់តាំងអ្នកត្រូវមកចូលរួមប្រជុំឱ្យមានការទទួលស្គាល់ច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារសម្រាប់កំណែទម្រង់ផង និងសម្រាប់ទំនាក់ទំនងការងារជាមួយអង្គភាពពាក់ព័ន្ធរបស់ក្រសួងផង។

ឯកឧត្តម **ហង់រ៉ូ វ៉ាកេន** អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ សំណូមពរឱ្យវិទ្យាស្ថានដាណឺម៉ាកសម្រាប់សិទ្ធិមនុស្ស (DIHR) ផ្តល់អ្នកជំនាញការបរទេសម្នាក់មក ជួយខាងអយ្យការអមសាលាឧទ្ធរណ៍ ពីព្រោះតាមក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ការកែទម្រង់ខាងអយ្យការមានលក្ខណៈធំធេងណាស់។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានសុំឱ្យឯកឧត្តម **ស៊ុយ ម៉ុងឈាង** ជួយពិចារណាលើសំណើរ របស់ឯកឧត្តម **ប្រុក សារឿន** និងសំណូមពររបស់ឯកឧត្តម **ហង់រ៉ូ វ៉ាកេន** ។

ឯកឧត្តម **ស៊ុយ ម៉ុងឈាង** បានលើកបញ្ជាក់អំពីការចាត់តាំងកន្លងមក មានភាពច្បាស់លាស់រួចហើយ គឺ សម្រាប់ក្រុមការងារបច្ចេកទេសចម្រុះ មានការសម្រេចចាត់តាំងរបស់សហប្រធាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ចំណែកឯការចាត់តាំងចំណុចទំនាក់ទំនង រវាងក្រសួង ស្ថាប័ន និងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ក៏ មានសេចក្តីសម្រេចច្បាស់លាស់រួចហើយដែរ។ ការដែលមានការខ្វះខាតអំពីទំនាក់ទំនងការងារនៅក្នុងក្រសួងអង្គភាព យើងខ្ញុំអាចជួយធ្វើអន្តរាគមន៍បានតិចតួចណាស់ ពីព្រោះជាបញ្ហាផ្ទៃក្នុងរបស់ក្រសួង។ ចំពោះការស្នើសុំជំនាញការបរទេសនោះ ឯកឧត្តមនឹងនាំពាក្យនេះទៅប្រាប់ DANIDA ដោយផ្ទាល់។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានសុំឱ្យឯកឧត្តម **ហង់វ៉ី រ៉ាកេន** ព្រាងលក្ខខណ្ឌយោង (TOR) សម្រាប់ជំនាញការ បរទេសនេះ តើសម្រាប់រយៈពេលប៉ុន្មាន ? ហើយមានការងារអ្វីខ្លះដែលត្រូវធ្វើ ?

ឯកឧត្តម **ប៊ុន ហុន** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ មានសំណូមពរឱ្យឈ្មោះអ្នកត្រូវចូលរួមក្នុងក្រុមការងារបច្ចេកទេសនេះយល់ដឹងច្បាស់ពីការងាររបស់ខ្លួន និងមានទំនាក់ទំនងជាមួយមន្ត្រីផ្សេងទៀតនៅក្នុងក្រសួង ដែលមានមុខងារនៅក្នុងក្រុមការងារនេះដែរ និងមួយវិញទៀតស្នើឱ្យអង្គភាពគ្រប់គ្រងគម្រោងជួយចម្លងជូននូវបញ្ជីឈ្មោះ ដើម្បីឱ្យស្គាល់គ្នាងាយស្រួលក្នុងការទំនាក់ទំនង។ ព្រមជាមួយគ្នានោះដែរ ឯកឧត្តមស្នើសុំឱ្យមានរៀបចំជាសេចក្តីណែនាំទាក់ទងដល់កំណែទម្រង់នេះ។

ចំពោះរចនាសម្ព័ន្ធគ្រប់គ្រងគម្រោង IMS នៅក្នុងឯកសារដែលបានចែកជូនក្នុងអង្គប្រជុំរួចហើយនោះ ឯកឧត្តម មានយោបល់ថា គួរបង្កើតក្រុមតែមួយបានហើយមិនបាច់មាន «វេទិកាជាដៃគូ» ផង និង« ក្រុមគម្រោង»ផងទេ ដោយមូលហេតុថា បើមានក្រុមការងារពីរនោះ អាចមិនយល់ដូចគ្នានាំឱ្យធ្វើអ្វីមិនកើត ដូច្នេះឯកឧត្តមស្នើឱ្យយកតែថ្នាក់បច្ចេកទេសមួយប៉ុណ្ណោះ។

លោក **សេង ស៊ីធុន្ធា** ចៅក្រមសាលាឧទ្ធរណ៍ បានមានប្រសាសន៍ថា ឯកឧត្តមបានចូលរួមពីរដងហើយ ក្នុងការប្រជុំប្រព័ន្ធសូចនាករនេះ។ ទាក់ទងនឹងការរៀបចំប្រព័ន្ធសូចនាករនេះ ឯកឧត្តមសួរថា តើការងារនេះមានលិខិតបទដ្ឋានសម្រាប់អនុវត្តឬទេ? ហើយឯកឧត្តមមានយោបល់ថា គួរតែមានបទដ្ឋានជាក់លាក់មួយសម្រាប់អនុវត្តគម្រោងនេះ ហើយរបាយការណ៍នៃកិច្ចប្រជុំក៏គួរចែកជូនឱ្យបានដឹងដែរ។

ឯកឧត្តម **ស៊ុយ ម៉ុងឈាង** បានយល់ស្របនឹងយោបល់លោក **សេង ស៊ីធុន្ធា** ថានឹងធ្វើសេចក្តីស្នើចាត់តាំងអ្នកមកចូលរួមក្នុងក្រុមការងារបច្ចេកទេសទៅឱ្យក្រសួង ស្ថាប័នដែល ត្រូវមកចូលរួមធ្វើការងារ ហើយបើក្រសួង ស្ថាប័នណាមិនអាចចាត់តាំងបាន សុំឱ្យផ្តល់ជាដំណឹងមកវិញតែប៉ុណ្ណោះ។ ចំពោះរឿងលិខិតបទដ្ឋានគតិយុត្តវិញ យើងមានឯកសារដែលរាជរដ្ឋាភិបាល បានសម្រេចឱ្យយើងអនុវត្តហើយ មិនបាច់មានលិខិតបទដ្ឋានផ្សេងទៀតទេ។ ឯកឧត្តមមានប្រសាសន៍បន្តទៀតថា មានរឿងខ្លះច្បាប់ចេញមកហើយ ប៉ុន្តែអនុវត្តមិនបានដោយខ្វះធនធានមនុស្ស និងថវិកាជាដើម ដូច្នេះការដាក់សូចនាករយើងក៏ត្រូវមើលស្ថានភាពជាក់ស្តែង និងកាលៈទេសៈផងដែរ។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានមានសំណូមពរថា បើអ្នកដែលត្រូវបានចាត់តាំងមិនអាចមកប្រជុំបាននោះ ចៅក្រមផ្សេងអាចមកប្រជុំជំនួសបាន ហើយចំពោះលិខិតបទដ្ឋាន ដែលទាក់ទងនឹងប្រព័ន្ធសូចនាករនោះយើងគ្មានទេ ប៉ុន្តែគម្រោងនេះ គឺបានទទួលសេចក្តីសម្រេចពីសម្តេចនាយករដ្ឋមន្ត្រីតាមរយៈការអនុម័តយល់ព្រមលើឯកសារកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់

និងតុលាការ ឆ្នាំ ២០០៥ រួចមកហើយ។ ចំពោះការបង្កើតក្រុមការងារ ឯកឧត្តមមានប្រសាសន៍ថា គួរតែមានពីរថ្នាក់ដូចដែលបានធ្វើសម្រាប់គម្រោងតុលាការគំរូទើបប្រសើរ ពីព្រោះតំណាងក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ដែលនៅក្នុងក្រុមការងារជាន់ខ្ពស់នោះ ពុំមានពេលគ្រប់គ្រាន់សម្រាប់គិតគូរអំពីការងារបច្ចេកទេសទេ។

ឯកឧត្តម **សួន លាងហៃ** នាយករងអង្គភាពគ្រប់គ្រងគម្រោង បានធ្វើការបញ្ជាក់ថា ការចូលរួមរបស់ក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការងារកំណែទម្រង់ច្បាប់ និងតុលាការធ្វើឡើងតាមរយៈការចាត់តាំង ០២ គឺការចាត់តាំងតំណាងនៅក្នុងក្រុមការងារបច្ចេកទេសចម្រុះ (TWG) និងការចាត់តាំងក្រុមការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ តាមក្រសួងមានជាអាទិ៍ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងអប់រំ និងក្រសួងពាណិជ្ជកម្ម។ ការអញ្ជើញឱ្យចូលរួមក្នុងការ ប្រជុំការងារផ្សេងៗរបស់កំណែទម្រង់ដូចជាអនុក្រុម ( Sub-Group ) ជាដើមគឺធ្វើឡើងតាមរយៈក្រុមការងារទាំងពីរនេះ។

អង្គភាពគ្រប់គ្រងគម្រោង មានគម្រោងនឹងបញ្ចប់ការរៀបចំសៀវភៅមគ្គុទ្ទេសតាមវិស័យ(Sector Manual) ហើយនឹងធ្វើការបណ្តុះបណ្តាលអំពីខ្លឹមសារ នៃសៀវភៅនោះជូនដល់អ្នកពាក់ព័ន្ធ ដើម្បីឱ្យបានយល់ច្បាស់ពីការងារកែទម្រង់ និងចូលរួមអនុវត្តការងារនេះឱ្យមានប្រសិទ្ធិភាព។ ចំពោះរបាយការណ៍អង្គភាពគ្រប់គ្រងគម្រោង នឹងខិតខំប្រឹងប្រែងជាបន្តទៅទៀតទៅតាមលទ្ធភាព ដែលអាចធ្វើទៅបាន។

លោក Tomas Martin, អ្នកគ្រប់គ្រងកម្មវិធីមកពី DIHRបានថ្លែងអំណរគុណចំពោះប្រធានអង្គប្រជុំ ដែលបានផ្តល់កិត្តិយសឱ្យលោកបានចូលរួមកិច្ចប្រជុំនេះ ក្នុងនាមជាអ្នកសង្កេតការណ៍។ លោកមានការចាប់អារម្មណ៍នឹងកិច្ច ប្រជុំដ៏មានសារសំខាន់នេះណាស់ ហើយលោកមានមោទនភាពថា DIHR មានកិត្តិយសណាស់ដែលបានធ្វើការជាមួយ នឹងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជានេះ។ លោកមានប្រសាសន៍បន្តទៀតថា ការរៀបចំប្រព័ន្ធសូចនាករ សម្រាប់វាស់វែងការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាចំណុចសំខាន់ណាស់។ DIHR នឹងជួយផ្នែកបច្ចេកទេសជំហ៊ានដំបូង (៦ខែ ទៅ៨ខែ) ដើម្បីរៀបចំផែនការ សម្រាប់អភិវឌ្ឍន៍ឯកសារគម្រោងសម្រាប់ប្រព័ន្ធសូចនាករ ដែលមានរួមបញ្ចូលនូវប្រតិទិន និងថវិកាសម្រាប់រយៈពេលបីឆ្នាំ ។

ជាចុងក្រោយលោកសង្ឃឹមថា ក្រុមការងារជាន់ខ្ពស់នឹងទទួលនូវការយល់ព្រមឯកភាពទៅលើទស្សនាទាន ហើយនឹងរៀបចំក្រុមការងារធ្វើការតែម្តង។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានធ្វើការបូកសរុបថា អង្គប្រជុំបានយល់ច្បាស់ច្រើនជាងមុន ហើយដូច្នេះអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នឹងរៀបចំធ្វើការតែងតាំងក្រុមការងារជាន់ខ្ពស់ សម្រាប់គម្រោងរៀបចំប្រព័ន្ធសូចនាករ សំរាប់តាមដានការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ហើយសូម

ថ្លែងអំណរគុណចំពោះកិច្ចសហការប្រត្តិបត្តការ គាំទ្ររបស់វិទ្យាស្ថានដាណឺម៉ាក និងឯកឧត្តម អស់លោក លោកស្រី ដែលបានចូលរួមក្នុងអង្គប្រជុំពេញអង្គទាំងមូលផងដែរ។

អង្គប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោង១២.០០ថ្ងៃត្រង់នាថ្ងៃដដែល។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧*

**បានឃើញ និងឯកភាព**

**ប្រធានអង្គប្រជុំ**

**អ្នកកត់ត្រា**

**ស៊ុំ ម៉ានិត** **សេង រ៉ាន់ដា**

**បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា**
**នាថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៧**

១ ឯកឧត្តម ស៊ុំ ម៉ានិត ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍
២ ឯកឧត្តម ហង់ រ៉ូរ៉ាកេន អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍
៣ ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង
៤ ឯកឧត្តម ប៊ុន ហុន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
៥ ឯកឧត្តម រៀល មួន ចៅក្រមតុលាការកំពូល
៦ ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង
៧ ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង
៨ ឯកឧត្តម ប្រុក សារឿន ប្រធាននីតិកម្មក្រសួងមហាផ្ទៃ
៩ លោកស្រី ឈូក សារ៉ុម ជំនួយការរដ្ឋបាល និងហិរញ្ញវត្ថុ
១០ លោក ហូរ ភ្រ័តា មន្រ្តី
១១ លោក ជ សៀក វែង CCJAP
១២ លោក សេង ស៊ីវុត្ថា តំណាងមកពីសាលាឧទ្ធរណ៍
១៣ លោក អ៊ីវ គឹមស្រ៊ី តំណាងប្រធានតុលាការភ្នំពេញ
១៤ Mr. Tomas Martin, DIHR
១៥ លោក រៀល សុភិន សមាជិកក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាឹតផ្ទៃ

១៦ កញ្ញា បូ ច័នគុលិកា មន្ត្រីការិយាល័យនីតិកម្ម ក្រសួងអប់រំ យុវជន និងកីឡា
១៧ លោក ឃ្លោក ដារ៉ា ប្រធានក្រុមគម្រោងសិទ្ធិមនុស្ស
១៨ លោក ជឹង ផេងស្រួយ ប្រធានក្រុមគម្រោងបណ្ណ័សារ និងព័ត៌មានវិទ្យា
១៩ លោកស្រី សេង វ៉ាន់ដា ជំនួយការរដ្ឋបាល និងហិរញ្ញវត្ថុ
២០លោក បួន សុមុនី ប្រធានក្រុមគម្រោងរដ្ឋបាល និងហិរញ្ញវត្ថុ
២១ លោក គង់ ផល្លៈ អនុប្រធានក្រុមកំណែទម្រង់ច្បាប់
២២ កញ្ញា ហ៊ួង សុកុល អនុប្រធានក្រុមគម្រោងរដ្ឋបាល និងហិរញ្ញវត្ថុ
២៣ លោកស្រី ស្រី ប៊ុណ្ណារ័ត្ន អនុប្រធានក្រុមគម្រោងបណ្ណ័សារ និងព័ត៌មានវិទ្យា
២៤ លោក ឆៃ លី អនុប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ
២៥ លោកស្រី យិន កក្កដា ជំនួយការរដ្ឋបាល និងហិរញ្ញវត្ថុ
២៦ លោក សួន វិរៈ មន្ត្រី
២៧ កញ្ញា ផាន ពិសីនលក្ខណ៍ មន្ត្រី